- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា
- **Law on the organization and the functioning of the congress of the national assembly and the senate**
- **Loi portant sur l’organisation et le fonctionnement du congrès de l’assemlée nationale et du sénat**
- បទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា

បច្ចុប្បន្នភាព ខែសីហា ឆ្នាំ២០២២

# ច្បាប់
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃ
# សមាជរដ្ឋសភានិងព្រឹទ្ធសភា

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១..**

ច្បាប់នេះ មានគោលដៅកំណត់ការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ស្របតាមមាត្រា ១១៦ថ្មី និងមាត្រា ១១៧ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២..**

សមាជរដ្ឋសភានិងព្រឹទ្ធសភា គឺជាការប្រជុំរួមគ្នានៃសមាជិករដ្ឋសភានិងព្រឹទ្ធសភា ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិក្នុងករណីចាំបាច់ ។

បន្ទាប់ទៅនេះ សមាជរដ្ឋសភានិងព្រឹទ្ធសភា ត្រូវកំណត់ហៅថា សមាជ ។

**មាត្រា ៣..**

បញ្ហាសំខាន់ៗ របស់ប្រទេសជាតិមាន ៖

-ការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ដល់ឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី ឬ

-ករណីប្រធានសក្តិ បណ្តាលឲ្យមានវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់ជាតិ និងប្រជាជន ឬ

-ករណីផ្សេងៗទៀត ដែលគណៈកម្មាធិការសមាជយល់ឃើញ

ថា ជាបញ្ហាសំខាន់របស់ប្រទេសជាតិ ។

## ជំពូកទី ២
## ការរៀបចំសមាជ

**មាត្រា ៤..**

ប្រធានព្រឹទ្ធសភា ជាប្រធានសមាជ ។

ក្នុងករណីប្រធានសមាជអវត្តមាន ឬមានធុរៈមិនអាចបំពេញមុខងារបាន ប្រធានរដ្ឋសភា ត្រូវទទួលភារកិច្ចជំនួស ។

តំណែងជំនួសប្រធានសមាជ ដូចមានចែងខាងលើនេះ អាចនឹងដូរទៅឥស្សរជនផ្សេងៗ តាមឋានានុក្រមដូចតទៅ :

-អនុប្រធានទី១ ព្រឹទ្ធសភា

-អនុប្រធានទី១ រដ្ឋសភា

-អនុប្រធានទី២ ព្រឹទ្ធសភា

-អនុប្រធានទី២ រដ្ឋសភា ។

**មាត្រា ៥..**

សមាជ ត្រូវធ្វើជាសាធារណៈ នៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរដ្ឋសភា លើកលែងតែមានការសម្រេចផ្សេងពីនេះ ចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ។

**មាត្រា ៦..**

សមាជមានគណៈកម្មាធិការសមាជមួយជាអ្នករៀបចំសមាជ ។

សមាសភាពគណៈកម្មាធិការសមាជមានដូចខាងក្រោម ៖

| | |
|---|---|
| ១-ប្រធានព្រឹទ្ធសភា | ប្រធាន |
| ២-ប្រធានរដ្ឋសភា | អនុប្រធាន |
| ៣-អនុប្រធានទី១ ព្រឹទ្ធសភា | សមាជិក |
| ៤-អនុប្រធានទី១ រដ្ឋសភា | សមាជិក |
| ៥-អនុប្រធានទី២ ព្រឹទ្ធសភា | សមាជិក |
| ៦-អនុប្រធានទី២ រដ្ឋសភា | សមាជិក ។ |

ប្រធានគណៈកម្មការទាំងអស់នៃព្រឹទ្ធសភានិងរដ្ឋសភា ជាជំនួយការគណៈកម្មាធិការសមាជ ។

**មាត្រា ៧..**

ប្រធានសមាជមានមុខងារដូចតទៅ :

ក-ធានាការប្រព្រឹត្តទៅនៃសមាជឲ្យបានត្រឹមត្រូវ តាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន

ខ-ដឹកនាំអង្គប្រជុំនៃសមាជ

គ-បើក និងលើកពេលប្រជុំនៃសមាជ

ឃ-ចាត់ចែងការពិភាក្សា ហើយចុះហត្ថលេខាលើកំណត់ហេតុនៃការប្រជុំសមាជ

ង-ញ៉ាំងឲ្យប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងនៃសមាជ

ច-រក្សាការពារសណ្តាប់ធ្នាប់ក្នុងពេលប្រជុំសមាជ

ធ-ជាតំណាងសមាជក្នុងការទាក់ទងជាមួយព្រះមហាក្សត្រ និង
អាជ្ញាធរសាធារណៈ ។

**មាត្រា ៨..**

អគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រូវទទួលបន្ទុកជាអគ្គលេខាធិ-
ការដ្ឋានសមាជ ។

**មាត្រា ៩..**

រាល់ការចំណាយសម្រាប់ដំណើរការសមាជ ជាបន្ទុករបស់
រដ្ឋសភា ។

## ជំពូកទី ៣
## ការប្រព្រឹត្តទៅនៃសមាជ

**មាត្រា ១០..**

ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋ-
មន្ត្រី អាចផ្តួចផ្តើមឲ្យមានការប្រជុំសមាជបាន ។

ប្រធានសមាជ អញ្ជើញសមាជិករដ្ឋសភា និងព្រឹទ្ធសភាឲ្យ
ចូលរួមប្រជុំសមាជ ។

**មាត្រា ១១..**

ការប្រជុំសមាជនឹងយកជាការបាន លុះត្រាតែមានកូរ៉ុមលើស
ពីពាក់កណ្តាលនៃសមាជិករដ្ឋសភាទាំងមូល និងកូរ៉ុមលើសពីពាក់
កណ្តាលនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១២..**

ការអនុម័តរបស់សមាជ ត្រូវយកតាមមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកសមាជទាំងមូល ។

**មាត្រា ១៣..**

សេចក្ដីសម្រេចរបស់សមាជ មានតម្លៃជាសេចក្ដីសម្រេចខ្ពស់បំផុតរបស់ប្រជាជាតិ ដែលត្រូវផ្សព្វផ្សាយជាសាធារណៈ និងចុះក្នុងរាជកិច្ច ។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**មាត្រា ១៤..**

សមាជប្រជុំលើកដំបូងរបស់ខ្លួន ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃយ៉ាងយូរ ក្រោយពេលច្បាប់នេះចូលជាធរមាន ដើម្បីពិនិត្យ និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល និងដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងដំណើរការនៃកិច្ចប្រជុំសមាជលើកដំបូងនេះ បទបញ្ជាផ្ទៃ-ក្នុងនៃរដ្ឋសភា ត្រូវយកមកអនុវត្តរហូតដល់សមាជអនុម័តបទបញ្ជា-ផ្ទៃក្នុងរបស់ខ្លួនបាន ។

# ឧបសម្ព័ន្ធ

# ព្រះរាជក្រម

នស/រកម/០២១១/០០៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១១៣/០០១/២០១១ កបធ.ច ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :



ROYAUME DU CAMBODGE
LE ... ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់ការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ស្របតាមមាត្រា ១១៦ថ្មី និងមាត្រា ១១៧ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

សមាជរដ្ឋសភានិងព្រឹទ្ធសភា គឺជាការប្រជុំរួមគ្នានៃសមាជិករដ្ឋសភានិងព្រឹទ្ធសភា ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិក្នុងករណីចាំបាច់ ។

បន្ទាប់ទៅនេះ សមាជរដ្ឋសភានិងព្រឹទ្ធសភា ត្រូវកំណត់ហៅថា សមាជ ។

**មាត្រា ៣.-**

បញ្ហាសំខាន់ៗរបស់ប្រទេសជាតិមាន :

- ការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ដល់ឯករាជ្យ អធិបតេយ្យ និង បូរណភាពទឹកដី ឬ
- ករណីប្រធានសក្តិ បណ្តាលឲ្យមានវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់ជាតិ និងប្រជាជន ឬ
- ករណីផ្សេងៗទៀត ដែលគណៈកម្មាធិការសមាជយល់ឃើញថា ជាបញ្ហាសំខាន់របស់ប្រទេសជាតិ ។

# ជំពូកទី ២
# ការរៀបចំសមាជ

**មាត្រា ៤.-**

ប្រធានព្រឹទ្ធសភា ជាប្រធានសមាជ ។

ក្នុងករណីប្រធានសមាជអវត្តមាន ឬ មានធុរៈមិនអាចបំពេញមុខងារបាន ប្រធានរដ្ឋសភាត្រូវទទួលភារកិច្ចជំនួស ។

តំណែងជំនួសប្រធានសមាជ ដូចមានចែងខាងលើនេះ អាចនឹងដូរទៅឥស្សរជនផ្សេងៗ តាមឋានានុក្រមដូចតទៅ:

- អនុប្រធានទី១ ព្រឹទ្ធសភា
- អនុប្រធានទី១ រដ្ឋសភា



Ksl

- អនុប្រធានទី២ ព្រឹទ្ធសភា
- អនុប្រធានទី២ រដ្ឋសភា ។

**មាត្រា ៥.–**

សមាជ ត្រូវធ្វើជាសាធារណៈ នៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរដ្ឋសភា លើកលែងតែមានការសម្រេចផ្សេងពីនេះ ចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ ។

**មាត្រា ៦.–**

សមាជ មានគណៈកម្មាធិការសមាជមួយជាអ្នករៀបចំសមាជ ។

សមាសភាពគណៈកម្មាធិការសមាជមានដូចខាងក្រោម :

| | |
|---|---|
| ១- ប្រធានព្រឹទ្ធសភា | ប្រធាន |
| ២- ប្រធានរដ្ឋសភា | អនុប្រធាន |
| ៣- អនុប្រធានទី១ ព្រឹទ្ធសភា | សមាជិក |
| ៤- អនុប្រធានទី១ រដ្ឋសភា | សមាជិក |
| ៥- អនុប្រធានទី២ ព្រឹទ្ធសភា | សមាជិក |
| ៦- អនុប្រធានទី២ រដ្ឋសភា | សមាជិក ។ |

ប្រធានគណៈកម្មការទាំងអស់នៃព្រឹទ្ធសភានិងរដ្ឋសភា ជាជំនួយការគណៈកម្មាធិការសមាជ ។

**មាត្រា ៧.–**

ប្រធានសមាជមានមុខងារដូចតទៅ:

ក- ធានាការប្រព្រឹត្តទៅនៃសមាជឲ្យបានត្រឹមត្រូវ តាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន

ខ- ដឹកនាំអង្គប្រជុំនៃសមាជ

គ- បើក និង លើកពេលប្រជុំនៃសមាជ

ឃ- ចាត់ចែងការពិភាក្សា ហើយចុះហត្ថលេខាលើកំណត់ហេតុនៃការប្រជុំសមាជ

ង- ញ៉ាំងឲ្យប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងនៃសមាជ

ច- រក្សាការពារសណ្តាប់ធ្នាប់ក្នុងពេលប្រជុំសមាជ

ឆ- ជាតំណាងសមាជក្នុងការទាក់ទងជាមួយព្រះមហាក្សត្រ និងអាជ្ញាធរសាធារណៈ ។

**មាត្រា ៨.–**

អគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រូវទទួលបន្ទុកជាអគ្គលេខាធិការដ្ឋានសមាជ ។

**មាត្រា ៩.-**

រាល់ការចំណាយសម្រាប់ដំណើរការសមាជ ជាបន្ទុករបស់រដ្ឋសភា ។

## ជំពូកទី ៣
## ការប្រព្រឹត្តទៅនៃសមាជ

**មាត្រា ១០.-**

ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី អាចផ្តួចផ្តើមឲ្យមានការប្រជុំសមាជបាន ។

ប្រធានសមាជ អញ្ជើញសមាជិករដ្ឋសភា និងព្រឹទ្ធសភាឲ្យចូលរួមប្រជុំសមាជ ។

**មាត្រា ១១.-**

ការប្រជុំសមាជនឹងយកជាការបាន លុះត្រាតែមានកូរ៉ុមលើសពីពាក់កណ្តាលនៃសមាជិករដ្ឋសភាទាំងមូល និងកូរ៉ុមលើសពីពាក់កណ្តាលនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១២.-**

ការអនុម័តរបស់សមាជ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកសមាជទាំងមូល ។

**មាត្រា ១៣.-**

សេចក្តីសម្រេចរបស់សមាជ មានតម្លៃជាសេចក្តីសម្រេចខ្ពស់បំផុតរបស់ប្រជាជាតិ ដែលត្រូវផ្សព្វផ្សាយជាសាធារណៈ និងចុះក្នុងរាជកិច្ច ។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**មាត្រា ១៤.-**

សមាជប្រជុំលើកដំបូងរបស់ខ្លួន ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃយ៉ាងយូរ ក្រោយពេលច្បាប់នេះចូលជាធរមាន ដើម្បីពិនិត្យនិងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ដោយមតិភាគច្រើនដាច់ខាតនៃ

ចំនួនសមាជិករដ្ឋសភាទាំងមូល និងដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងដំណើរការនៃកិច្ចប្រជុំសមាជលើកដំបូងនេះ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ត្រូវយកមកអនុវត្ត រហូតដល់សមាជអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនបាន ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

៣រល.១១០២.១៧៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ ១៥៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ២០១១

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

6/6/12

# Law

# On

# The Organization and the Functioning

# Of the Congress of

# The National Assembly and the Senate

# Chapter I
# General Provisions

## Article 1

This law aims at determining the organization and the functioning of the Congress of the National Assembly and the Senate in accordance with Art.116 (New) and 117 (New) of the Constitution of the Kingdom of Cambodia.

## Article 2

The Congress of the National Assembly and the Senate shall be the joint session of the members of the National Assembly and the Senate in order to solve the major issues of the nation when it is necessary.

The Congress of the National Assembly and the Senate shall hereinafter be referred as the 'Congress'.

## Article 3

The major issues of the nation include:

- severe threats against the independence, sovereignty and territorial integrity; or
- cases of force majeure which cause serious damage to the nation and the people; or
- any other circumstance which is also considered by the Congress Committee as a major issue of the nation.

## Chapter II
## The Organization of the Congress

### Article 4

The Senate President shall be the Congress President.

In case of absence of the President of the Congress or in case he/she cannot fulfill this function, the National Assembly President shall be his/her replacement.

Hierarchically, the above-mentioned Congress Presidency may be devolved to the following dignitaries:

- First Vice-President of the Senate
- First Vice-President of the National Assembly
- Second Vice- President of the Senate
- Second Vice-President of the National Assembly

### Article 5

The Congress shall be held in public, in the Royal Capital of the Kingdom of Cambodia, at the National Assembly hall, except when stipulated otherwise in the letters of summons due to special circumstances.

### Article 6

The Congress shall have a Congress Committee to help with the organization.

The composition of the Congress Committee shall be as follow:

- President of the Senate, President
- The President of the National Assembly, Vice-President
- First Vice-President of the Senate, Member
- First Vice-President of the National Assembly, Member
- Second Vice-President of the Senate, Member
- Second Vice-President of the National Assembly, Member

All chairmen of the Senate and the National Assembly Commissions are the assistants of the Congress Committee.

**Article 7**

The President of the Congress shall fulfill the following duties:

- guarantee a proper functioning of the Congress in accordance with the Constitution and applicable laws;
- preside over the Congress sessions;
- open and adjourn the Congress sessions;
- manage the floor debates and sign on the session minutes;

- enforce the implementation of the Congress Internal Regulations;
- maintain orders during the Congress sessions; and
- Represent the Congress in relationship with the King and public authorities.

**Article 8**

The Secretariat General of the National Assembly shall assume the responsibility as the Secretariat General of the Congress

**Article 9**

The National Assembly shall be responsible for all expenses for the functioning of the Congress.

## Chapter III
## The Functioning of the Congress

**Article 10**

The King, the President of the Senate, the President of the National Assembly, or Prime Minister may propose for a session of the Congress.

The President of the Congress shall summon the members of the National Assembly and the Senate to attend the sessions.

**Article 11**

The Congress session shall only be valid when the quorum of more than half of all National Assembly members and more than half of all senators is achieved.

**Article 12**

A resolution of the Congress shall only be valid by an absolute majority vote of all present members.

**Article 13**

A resolution of the Congress is the highest national resolution, and has authority above all other resolutions. Such resolution shall be publicly disseminated and published in the Royal Gazette.

## Chapter IV
## Transitional Provisions

**Article 14**

The first session of the Congress shall be convened within sixty (60) days at the latest date after this law comes into effect in order to review and adopt its Internal Regulations by an absolute majority vote of all members of the National Assembly and the Senate.

The internal regulation of the National Assembly shall be used for the first convening of the Congress until its internal regulation is adopted.

# Loi
# Portant sur l'organisation et
# Le fonctionnement du Congrès de
# l'Assemblée Nationale et du Sénat

## Chapitre I
## Dispositions générales

### Article1

La présente loi a pour objet de fixer l'organisation et le fonctionnement du Congrès de l'Assemblée Nationale et du Sénat conformément aux articles 116 nouveaux et 117 nouveaux de la Constitution du Royaume du Cambodge.

### Article2

Le Congrès de l' Assemblée Nationale et du Sénat est la réunion conjointe de l'Assemblée Nationale et du Sénat dans le but de résoudre les problèmes importants du pays en cas de nécessité.

La réunion conjointe de l'Assemblée Nationale et du Sénat est désormais dénommée Le Congrès.

### Article3

Sont considérés comme étant des problèmes importants du pays:

- toute menace sérieuse à l'indépendance, à la souveraineté et à l'intégrité territoriale ou
- tout cas de force majeure provoquant une catastrophe sérieuse pour la Nation et le peuple ou
- tout autre cas que le Comité du Congrès considère comme problème important du pays.

## Chapitre II
## Organisation du Congrès

### Article 4

Le Président du Sénat est le Président du Congrès.

Dans le cas où le Président du Congrès est absent ou ne peut pas assumer ses fonctions, le Président de l'Assemblée Nationale le remplace.

Si celui-ci est absent ou ne peut assumer ses fonctions, la présidence du Congrès peut être confiée aux personnalités suivantes et dans l'ordre suivant :

- le premier vice président du Sénat
- le premier vice président de l'Assemblée Nationale
- le deuxième vice président du Sénat
- le. deuxième vice président de l'Assemblée Nationale.

### Article 5

Le Congrès se réunit en séance publique, dans la Capitale du Royaume du Cambodge, dans la salle des sessions de l'Assemblée Nationale, sauf décision différente précisée dans l'acte de convocation en fonction des circonstances.

### Article 6

Le Congrès dispose d'un Comité chargé d'organiser le Congrès

La composition du Comité du congrès est la suivante :

1 - le président du Sénat Président

2 - le président de l'Assemblée Nationale
vice- président

3 - le premier vice président du Sénat membre

4 - le premier vice président de l'Assemblée Nationale
membre

5 - le deuxième vice président du Sénat membre

6 - le deuxième vice président de l'Assemblée Nationale membre

Les Présidents des Commissions du Sénat et de l'Assemblée assistent du Comitè du Congrès.

**Article 7**

Le Président du Congrès a pour missions :

a- d'assurer le fonctionnement régulier du Congrès conformément à la Constitution et aux lois en vigueur ;
b- de présider la réunion du Congrès ;
c- d'ouvrir et de reporter la séance du Congrès ;
d- de diriger les débats et de signer les comptes-rendus de la réunion du Congrès ;
e- de faire respecter le règlement intérieur du Congrès ;
f- de maintenir l'ordre public en séance du Congrès ;
g- de représenter le Congrès dans ses relations avec le Roi et les autorités publiques.

**Article 8**

Le secrétariat général de l'Assemblée Nationale est le secrétariat général du Congrès.

### Article 9

Les dépenses engagées pour le fonctionnement du Congrès sont prises en charge par l'Assemblée Nationale.

## Chapitre 3
## Fonctionnement du Congrès

### Article 10

Le Roi, le Président du Sénat, le Président de l'Assemblée Nationale, le Premier Ministre peut prendre l'initiative de la réunion du Congrès.

Le Président du Congrès convoque les membres de l'Assemblée Nationale et le membres du Sénat à la réunion du Congrès.

### Article 11

La séance du Congrès n'est valable que lorsque plus de la moitié des députés et plus de la moitié des sénateurs sont présents.

### Article 12

Le Congrès adopte ses décisions à la majorité absolue des membres du congrès du composant.

### Article 13

La décision du Congrès est considérée comme la plus haute décision de la Nation, et doit être répandre publiquement et doit être publiée au Journal Officiel.

## Chapitre 4
## Disposition transitoire

### Article 14

La première session du Congrès parlementaire s'ouvre soixante jours au plus tard après l'entrée en vigueur de la présente loi pour examiner le règlement intérieur du Congrès et l'adopter à la majorité absolue des membres de l'Assemblée Nationale et à la majorité absolue des membres du Sénat.

Pour la tenue de la première séance du Congrès parlementaire, le règlement intérieur de l'Assemblée Nationale est applicable jusqu'à ce que le Congrès adopte son propre règlement.

# បទបញ្ញាផ្ទៃក្នុងនៃ
# សមាជរដ្ឋសភា និងព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាជរដ្ឋសភា និងព្រឹទ្ធសភា

# បទបញ្ជាផ្ទៃក្នុងនៃ
# សមាជរដ្ឋសភា និងព្រឹទ្ធសភា

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១..**

បទបញ្ញាផ្ទៃក្នុងនេះ កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា ព្រមទាំងនីតិវិធីទាំងឡាយដែលត្រូវប្រើក្នុងសមាជ ។

**ប្រការ ២..**

សមាជរដ្ឋសភា និងព្រឹទ្ធសភា ត្រូវស្ថិតនៅក្រោមអធិបតីភាពនៃប្រធានព្រឹទ្ធសភា ។ សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភាជាសមាជិកនៃអង្គសមាជ ។

## ជំពូកទី ២
## អំពីប្រធាន អនុប្រធាន និងគណៈកម្មាធិការសមាជ

**ប្រការ ៣..**

សមាសភាពគណៈកម្មាធិការសមាជមានដូចតទៅ :

| | |
|---|---|
| ១-ប្រធានព្រឹទ្ធសភា | ប្រធាន |
| ២-ប្រធានរដ្ឋសភា | អនុប្រធាន |
| ៣-អនុប្រធានទី១ ព្រឹទ្ធសភា | សមាជិក |

៤-អនុប្រធានទី១ រដ្ឋសភា សមាជិក

៥-អនុប្រធានទី២ ព្រឹទ្ធសភា សមាជិក

៦-អនុប្រធានទី២ រដ្ឋសភា សមាជិក ។

ប្រធានគណៈកម្មាធិការទាំងអស់នៃព្រឹទ្ធសភា និងរដ្ឋសភា ជាជំនួយការគណៈកម្មាធិការសមាជ ។

**ប្រការ ៤..**

ប្រធានសមាជមានមុខងារដូចតទៅ :

ក-ធានាការប្រព្រឹត្តទៅនៃសមាជឲ្យបានត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

ខ-ដឹកនាំអង្គប្រជុំសមាជ និងគណៈកម្មាធិការសមាជ ។

គ-បើក និងលើកពេលប្រជុំសមាជ ។

ឃ-ចាត់ចែងការពិភាក្សា ហើយចុះហត្ថលេខាលើកំណត់ហេតុនៃអង្គប្រជុំ និងឯកសារផ្សេងទៀតដែលពាក់ព័ន្ធនឹងការសម្រេចរបស់សមាជ ។

ង-ញ៉ាំងឲ្យប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា ។

ច-រក្សាការពារសណ្តាប់ធ្នាប់ក្នុងពេលប្រជុំសមាជ ។

ឆ-តំណាងសមាជក្នុងការទាក់ទងជាមួយព្រះមហាក្សត្រ និងអាជ្ញាធរសាធារណៈ ។

**ប្រការ ៥..**

អនុប្រធានសមាជ ជួយធ្វើការប្រធានទៅតាមការបែងចែកការកិច្ចពីប្រធាន ។ ក្នុងករណីប្រធានសមាជអវត្តមាន ឬ មានធុរៈមិនអាចបំពេញមុខងារបាន អនុប្រធានធ្វើការជួសប្រធានក្នុងឋានៈជាប្រធានស្តីទី តាមលិខិតផ្ទេរសិទ្ធិ ។

តំណែងជំនួសប្រធានសមាជ អាចនឹងជូរទៅឥស្សរជនផ្សេងៗតាមឋានានុក្រមដូចតទៅ :

១-អនុប្រធានទី១ ព្រឹទ្ធសភា

២-អនុប្រធានទី១ រដ្ឋសភា

៣-អនុប្រធានទី២ ព្រឹទ្ធសភា

៤-អនុប្រធានទី២ រដ្ឋសភា ។

**ប្រការ ៦..**

គណៈកម្មាធិការសមាជ ទទួលពិនិត្យ និងសម្រេចបញ្ហាសំខាន់របស់ប្រទេសជាតិ ដែលត្រូវដាក់ជារបៀបវារៈរបស់អង្គប្រជុំសមាជ ។

# ជំពូកទី ៣
# អំពីអគ្គលេខាធិការដ្ឋានសមាជ

**ប្រការ ៧..**

*អគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រូវទទួលបន្ទុកជាអគ្គលេខាធិការដ្ឋានសមាជ ។*

*អគ្គលេខាធិការដ្ឋានសមាជ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់គណៈកម្មាធិការសមាជទទួលបន្ទុកកិច្ចការរដ្ឋបាល សន្តិសុខ ហិរញ្ញវត្ថុ និងសេវាទាំងឡាយរបស់សមាជ ។*

*ភារកិច្ចសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានសមាជមាន :*

*ក-ធ្វើគម្រោងថវិកា បែបបទនៃចំណូល និងចំណាយថវិកា និងរបាយការណ៍ទូទាត់ចំណូល ចំណាយថវិការបស់សមាជ។*

*ខ-ធ្វើកំណត់ហេតុប្រជុំសមាជ និងប្រជុំគណៈកម្មាធិការសមាជ ។*

*គ-ផ្តល់គ្រប់កំណត់ហេតុ ឬ សេវាខាងនីតិវិធី ច្បាប់ជំនាញ និង បច្ចេកទេសជូនគណៈកម្មាធិការសមាជ និងសមាជិកសមាជ ។*

*ឃ-រក្សាកំណត់ហេតុ និងឯកសារទាំងអស់របស់សមាជ មិនឲ្យបែកខ្ចរខ្ចាយទៅខាងក្រៅដោយគ្មានការអនុញ្ញាតពីប្រធានសមាជឡើយ ។*

**ប្រការ ៨..**

អគ្គលេខាធិការដ្ឋានសមាជ ត្រូវដឹកនាំដោយអគ្គលេខាធិការរដ្ឋសភា និងអមដោយអគ្គលេខាធិការរងតាមការចាំបាច់ ។

## ជំពូកទី ៤
## អំពីរបៀបវារៈ

**ប្រការ ៩..**

គណៈកម្មាធិការសមាជ ជាអ្នករៀបចំរបៀបវារៈសម្រាប់កិច្ចប្រជុំសមាជ ។

**ប្រការ ១០..**

របៀបវារៈអង្គប្រជុំសមាជមានសេចក្ដីជាលំដាប់មុនក្រោយដូចតទៅនេះ :

-លិខិតផ្ដួចផ្ដើមរបស់តស្សូរជនជាន់ខ្ពស់ដូចមានបញ្ញត្តក្នុងកថាខ័ណ្ឌទី ១ មាត្រា ១០ នៃច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា

-បញ្ហាសំខាន់ៗ ដែលគណៈកម្មាធិការសមាជ បានសម្រេចរៀបក្នុងរបៀបវារៈ ។

## ជំពូកទី ៥
## អំពីរបៀបប្រជុំសមាជ

**ប្រការ ១១..**

អាសនានុក្រមនៃសមាជិកសមាជ ត្រូវរៀបជាក្រុមៗ តាមគណបក្សនយោបាយពីមុខទៅក្រោយ ។ ក្រុមនីមួយៗ ត្រូវមានសមាជិកយ៉ាងតិចដប់ប្រាំរូប ។ សមាជិកព្រឹទ្ធសភា និងតំណាងរាស្ត្រមួយរូបអាចចូលជាសមាជិករបស់ក្រុមតែមួយប៉ុណ្ណោះ ។ ក្រុមនីមួយៗ ត្រូវមានប្រធានមួយរូប អនុប្រធានមួយរូប ។ គណបក្សនយោបាយណាមានអាសនៈយ៉ាងតិចដប់ប្រាំ ត្រូវជ្រើសរើសក្រុមណាមួយដែលខ្លួនពេញចិត្តនៅជាមួយ ។

បញ្ជីរាយនាមរបស់ក្រុមសមាជិកសមាជ នៃគណបក្សនយោបាយ ត្រូវផ្ញើជូនប្រធានសមាជ ។

**ប្រការ ១២..**

ការកំណត់ថ្ងៃប្រជុំ ត្រូវធ្វើជាលិខិតផ្ញើជូនសមាជិកសមាជ ។ សមាជ ត្រូវធ្វើនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជាក្នុងសាលប្រជុំ រដ្ឋសភា លើកលែងតែមានការសម្រេចផ្សេងពីនេះចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ ។

**ប្រការ ១៣..**

លិខិតអញ្ជើញ ត្រូវមានភ្ជាប់ជាមួយនូវរបៀបវារៈប្រជុំ វៀរ-លែងតែក្នុងករណីប្រញាប់ ។

**ប្រការ ១៤..**

ក្នុងពេលប្រជុំសមាជនីមួយៗ លេខាធិការស្រង់ឈ្មោះសមាជិកសមាជដែលអវត្តមាន ។ ឈ្មោះសមាជិកដែលអវត្តមានគ្មានច្បាប់អនុញ្ញាត ត្រូវប្រកាសក្នុងអង្គប្រជុំ ។

**ប្រការ ១៥..**

ការប្រជុំសមាជ នឹងយកជាការបានលុះត្រាតែមានកូរ៉ុមលើសពីពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល និងលើសពីពាក់កណ្ដាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

បើកូរ៉ុមមិនគ្រប់ក្នុងរយៈពេល ១៥ (ដប់ប្រាំ) នាទី ក្រោយពេលកំណត់ចាប់ផ្ដើមការប្រជុំប្រធានសមាជ ត្រូវលើកពេលប្រជុំ ។

**ប្រការ ១៦..**

សមាជ ត្រូវប្រជុំជាសាធារណៈ ។ កំណត់ហេតុនៃការប្រជុំសមាជមានកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្ដារ ។ កំណត់-ហេតុទាំងអស់ ត្រូវតម្កល់ទុកក្នុងអគ្គលេខាធិការដ្ឋានរដ្ឋសភា ។

សមាជ អាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីព្រះមហាក្សត្រ ពីប្រធានព្រឹទ្ធសភា ពីប្រធានរដ្ឋសភា ឬ ពីនាយករដ្ឋមន្ត្រី ។

**ប្រការ ១៧..**

បើមានបញ្ហាអ្វីនឹងថ្លែងជម្រាបអង្គសមាជនោះ ប្រធានអាចថ្លែងមុននឹងចាប់ធ្វើការតាមរបៀបវារៈ ។

**ប្រការ ១៨..**

មុននឹងចាប់ផ្ដើមកិច្ចប្រជុំនីមួយៗ សមាជអនុម័តរបៀបវារៈ និងសមាសភាពលេខាធិការអង្គប្រជុំចំនួនបួនរូប ដែលពីររូបជាសមាជិករដ្ឋសភា និងពីររូបជាសមាជិកព្រឹទ្ធសភា ។

**ប្រការ ១៩..**

លេខាធិការអង្គប្រជុំសមាជ ជួយប្រធានសមាជលើកិច្ចការដូចតទៅ :

-ពិនិត្យកូរ៉ុមសម្រាប់ប្រជុំ និងនៅពេលអនុម័ត

-កត់ឈ្មោះសមាជិកសមាជ ដែលសុំបញ្ចេញយោបល់តាមលំដាប់មុនក្រោយ

-រៀបចំការបោះឆ្នោតចំហ ឬសម្ងាត់

-បំពេញកិច្ចការផ្សេងទៀត តាមសេចក្ដីណែនាំរបស់ប្រធានសមាជ ។

**ប្រការ ២០..**

ក្នុងការជជែកពិភាក្សា វាគ្មិនត្រូវនិយាយឆ្លាស់គ្នា អ្នកគាំទ្រនិយាយម្តងរួចអ្នកជំទាស់និយាយម្តង ។

**ប្រការ ២១..**

តាមគោលការណ៍ រយៈពេលនិយាយសម្រាប់សមាជិកសមាជ ត្រូវមានកំណត់ ហើយត្រូវនិយាយតែពីប្រធានបទដែលកំពុងពិភាក្សា ។ បើនិយាយក្រៅប្រធានបទ ប្រធានត្រូវរំលឹកឲ្យធ្វើតាមរបៀបខាងលើនេះវិញ ។ បើសមាជិកសមាជនោះ នៅចចេសនិយាយក្រៅប្រធានបទដដែល ប្រធានអង្គប្រជុំអាចបញ្ឈប់វាគ្មិននោះកុំឲ្យនិយាយបន្តទៅទៀត ។

**ប្រការ ២២..**

សមាជិកសមាជដែលបានចុះឈ្មោះសុំបញ្ចេញយោបល់និយាយបានជប់នាទីយ៉ាងយូរ ។ សមាជិកដែលគ្រាន់តែឆ្លើយតបនិយាយបានត្រឹមតែប្រាំនាទី ។ បើប្រធានយល់ឃើញថាជាការចាំបាច់ ឬជាការមានប្រយោជន៍ក្នុងការពិភាក្សាអាចអនុញ្ញាតបន្ថែមប្រាំនាទី ។ ការបន្ថែមនេះ អាចអនុញ្ញាតឲ្យបន្តបានពីរដងក្នុងប្រធានបទតែមួយ ។

**ប្រការ ២៣..**

បទប្បញ្ញត្តិអំពីការចុះឈ្មោះសុំនិយាយជាលំដាប់គ្នា និង អំពីកំណត់រយៈពេលនិយាយនេះប្រើសម្រាប់តែសមាជិកសមាជ មិនប្រើសម្រាប់ម្ចាស់សំណើទេ ។

**ប្រការ ២៤..**

ហាមមិនឲ្យនិយាយកាត់ពាក្យអ្នកដទៃ មិនឲ្យនិយាយវាយប្រហារលើបុគ្គល មិនឲ្យសម្ដែងអាការៈផ្សេងៗ ដែលនាំឲ្យខូចសណ្ដាប់ធ្នាប់ ។

## ជំពូកទី ៦
## អំពីការរក្សាសេចក្ដីស្ងប់ស្ងាត់ក្នុងពេលប្រជុំ

**ប្រការ ២៥..**

ប្រធានសមាជមានភារៈរក្សាការពារ មិនឲ្យមានភាពជ្រួលច្របល់ និង ភយន្តរាយខាងក្នុងក្ដីមកពីខាងក្រៅក្ដីដែលកើតមានឡើងដល់សមាជ ។ ដើម្បីធ្វើឲ្យសម្រេចកិច្ចនេះ ប្រធានអាចសុំអន្តរាគមន៍ពីកម្លាំងនគរបាល ឬ កម្លាំងទ័ព ។

## ជំពូកទី ៧
## អំពីការខានមកប្រជុំ

**ប្រការ ២៦..**

*សមាជិកសមាជមិនអាចអវត្តមាន ដោយមិនអាចមានការអនុញ្ញាតពីប្រធានសមាជបានឡើយ ។ ក្នុងករណីបន្ទាន់ ត្រូវជូនដំណឹងមកប្រធានសមាជ តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន ។*

## ជំពូកទី ៨
## អំពីការបញ្ចេញមតិ

**ប្រការ ២៧..**

*ក្នុងបញ្ហាសំខាន់ៗទាំងឡាយដែលសមាជត្រូវពិនិត្យ សមាជបញ្ចេញមតិ ដោយវិធីបីយ៉ាង គឺដោយលើកដៃ ដោយបោះឆ្នោតចំហ ឬបោះឆ្នោតសម្ងាត់ ។*

*វិធីបញ្ចេញមតិដោយលើកដៃ ឬ ដោយបោះឆ្នោតចំហខាងលើនេះអាច ធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិច ។*

**ប្រការ ២៨..**

នីតិវិធីនៃការបោះឆ្នោតបញ្ចេញមតិ ដែលមានចែងក្នុងបទបញ្ញាផ្ទៃក្នុងនៃរដ្ឋសភា ប្រការ ៣៧ ប្រការ ៣៨ ថ្មី និង ប្រការ ៣៩ ត្រូវយកមកប្រើសម្រាប់ការ បោះឆ្នោតបញ្ចេញមតិនៅក្នុងអង្គសមាជផងដែរ ។

ការបោះឆ្នោតសម្ងាត់ ត្រូវកំណត់ដោយគណៈកម្មាធិការសមាជ ។

**ប្រការ ២៩..**

ការអនុម័តរបស់សមាជ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកសមាជទាំងមូល ។

ក្រោយបានលទ្ធផលនៃការបញ្ចេញមតិរួចហើយ ប្រធានសមាជ ត្រូវប្រកាសថាសមាជបានអនុម័តយល់ព្រមហើយ ឬថាសមាជបានអនុម័តមិនយល់ព្រមទេ ។

## ជំពូកទី ៩
## អំពីវិន័យ

**ប្រការ ៣០..**

*ទណ្ឌកម្មខាងវិន័យ ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ប្រការ ៧៣ ប្រការ ៧៤ ប្រការ ៧៥ និង ប្រការ ៧៩ ត្រូវយកមកអនុវត្តចំពោះសមាជិកសមាជផងដែរ ។*

## ជំពូកទី ១០
## អំពីការកែប្រែបទបញ្ជាផ្ទៃក្នុង

**ប្រការ ៣១..**

*បទបញ្ជាផ្ទៃក្នុងនេះនឹងកែប្រែបាន លុះត្រាតែមានសេចក្តីស្នើសុំពីសមាជិកមួយភាគបួនយ៉ាងតិចនៃចំនួនសមាជិកសមាជទាំងមូល ហើយត្រូវអនុម័តយល់ព្រមដោយសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកសមាជទាំងមូល ។*

បទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភា និងព្រឹទ្ធសភានេះ ត្រូវបានសមាជរដ្ឋសភា និងព្រឹទ្ធសភាលើកដំបូងអនុម័ត នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១១

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១១

**ប្រធានសមាជស្តីទី**



**សម្តេចស៊ីសុវត្ថិ ជីវ័នមុនីរ័ក្ស**